Sustainable Development Verified Impact Standard

# គម្រោងរេដបូកសំកុស

## លេខអត្តសញ្ញាណគម្រោង: ៣៣៤១

WILDLIFEALLIANCE
Direct Protection to Forests & Wildlife

ឯកសាររៀបចំដោយ

អង្គការសម្ព័ន្ធមិត្តសត្វព្រៃ

ដោយមានគោលបំណងជួយរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវគោលដៅបរិស្ថានរបស់ខ្លួនសម្រាប់កំណើនសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព លើកកម្ពស់ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ អភិរក្សជីវចម្រុះ និងបង្កើតឲ្យមានជម្រើសជីវភាពរស់នៅ ស្របតាមផែនការរបស់អង្គការសហប្រជាជាតិ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ និងរិចរិលព្រៃឈើ (REDD+) ។ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានបង្កើតគម្រោងរេដបូកសំកុសឡើង ដែលគម្រោងនេះរួមបញ្ចូលតំបន់ការពារទេសភាពចំនួនបីដូចជា៖ ដែនជម្រកសត្វព្រៃភ្នំសំកុស ជាតំបន់ការពារទេសភាពនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ដែលគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ២០២ ៤៥១ ហិត ច្រករបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិភ្នំក្រវាញ ដែលមានផ្ទៃដី ៨២ ៧៣៥ ហិត និងតំបន់ភាគខាងជើងនៃឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូងស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ដែលមានផ្ទៃដី ១២ ២១១ ហិត។ ទំហំផ្ទៃដីសរុបនៃតំបន់គណនេយ្យគម្រោងគឺ ២៨២ ៧១៨ ហិត។

តំបន់ការពារធម្មជាតិទាំងបីនេះរួមមានដែនជម្រកសត្វព្រៃភ្នំសំកុស ច្រករបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិភ្នំក្រវាញ និងឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូងស្ថិតនៅចំចំណុចសំខាន់បំផុតនៃតំបន់ជួរភ្នំក្រវាញដែលជាទីតាំងសំបូរដោយជីវចម្រុះដ៏សំខាន់នៃឧបទ្វីបឥណ្ឌូ-ភូមារបស់ប្រទេសកម្ពុជា។ ឧបទ្វីបឥណ្ឌូ-ភូមាជាទីតាំងសំបូរដោយជីវចម្រុះដ៏សំខាន់មួយ នៅលើពិភពលោក។ យោងតាមអង្គការអាយ-យូ-ស៊ី-អិន តំបន់នេះស្ថិតក្នុងចំណាត់ថ្នាក់ជាទីកន្លែងអភិរក្សជីវចម្រុះដ៏សំខាន់ជាងគេក្នុងចំណោមទីកន្លែងអភិរក្សជីវចម្រុះដ៏សំខាន់ៗជាងគេទាំង១០ដែលមិនអាចជំនួសបាន ប៉ុន្តែជាអកុសល តំបន់នេះជាប់ចំណាត់ថ្នាក់ទីប្រាំសម្រាប់ការគំរាមកំហែង ពីព្រោះមានតែ ៥% នៃជម្រកធម្មជាតិរបស់វាប៉ុណ្ណោះដែលមាននៅសេសសល់។

តំបន់គម្រោងរួមមាន ២៦ ភូមិគោលដៅ ស្ថិតនៅក្នុង ៨ ឃុំ, ៤ ស្រុក និង ២ ខេត្ត។ សហគមន៍ដែលកំពុងលូតលាស់ទាំងនេះដែលមានប្រហែល ៣ ០៤១ គ្រួសារ និងប្រជាជន ១៣ ២៦១ នាក់ បង្ហាញពីការគំរាមកំហែងដ៏ធំបំផុតចំពោះគម្រោងរេដបូកសំកុស។ ការគំរាមកំហែងទាំងនោះបានបង្ហាញខ្លួនក្នុងទម្រង់ដូចជាការឈូសឆាយដីព្រៃខុសច្បាប់ ការទន្ទ្រានដីព្រៃ ការកាប់ឈើខុសច្បាប់ និងការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធជនបទមិនបានល្អ ។

សេណារីយ៉ូជាមូលដ្ឋានដែលត្រូវបានកំណត់ គឺការបំប្លែងប្រព័ន្ធអេកូឡូស៊ីដើម ពីស្ថានភាពជាព្រៃឈើធម្មជាតិឲ្យទៅជាស្ថានភាពមិនមានព្រៃឈើ (កសិកម្ម)។ ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងដល់ដែនជម្រកសត្វព្រៃភ្នំសំកុស និងច្រករបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិភ្នំក្រវាញ អង្គការសម្ព័ន្ធមិត្តសត្វព្រៃជាមួយនិងក្រសួងបរិស្ថាន (MOE) បានសម្រេចបង្កើតគម្រោងរេដបូកសំកុសនេះឡើង។ ការការពារនៃគម្រោងរេដបូកសំកុសនឹងទទួលបានតាមរយៈការរចនា និងការផ្តល់ប្រព័ន្ធប្រព័ន្ធគ្រប់គ្រងឧទ្យានជាតិសកម្មជាពិសេសសម្រាប់ដែនជម្រកសត្វព្រៃភ្នំសំកុស ដែលរួមបញ្ចូលការល្បាតដោយផ្ទាល់នៅតាមតំបន់គម្រោង និងនៅខាងក្នុងតំបន់គណនេយ្យភាពគម្រោង។ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ និងមន្ត្រីឧទ្យានុរក្សរបស់ក្រសួងបរិស្ថាន បាននិងកំពុងល្បាតតំបន់ធំ ៗ នៅក្នុងតំបន់គណនេយ្យគម្រោង តាំងពីឆ្នាំ ២០១៩ មកម្ល៉េះ ដោយសារដែនជម្រកសត្វព្រៃនេះមានព្រំប្រទល់ជាប់នឹងគម្រោង រេដបូកជួរភ្នំក្រវាញខាងត្បូង (VCS Project ID 1748) ។

គម្រោងនេះក៏នឹងបង្កើតឱកាសមុខរបរចិញ្ចឹមជីវិតប្រកបដោយចីរភាព បង្កើតជម្រើសបង្កើតប្រាក់ចំណូល (IGAs) និងគំនិតផ្តួចផ្តើមដើម្បីជំរុញការវិនិយោគអាជីវកម្មក្នុងស្រុកដែលត្រូវបានរចនាឡើងដើម្បីកាត់បន្ថយសម្ពាធលើបរិស្ថាន ស្របពេលបង្កើនសុខុមាលភាពដល់សហគមន៍។ គម្រោងនេះនឹងដោះស្រាយបញ្ហាសន្តិសុខស្បៀងអាហារ/អាហារូបត្ថម្ភ កែលម្អបរិក្ខារសុខាភិបាល និងអប់រំ ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន។

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ ២០១៥។ ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាចំនួន ១៨ រដ្ឋាភិបាលបានផ្តល់អាទិភាពដល់គោលដៅចំនួន ៦ ដូចខាងក្រោម៖ ការអប់រំ ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច កាត់បន្ថយវិសមភាព ការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ សន្តិភាព និងស្ថាប័ន និងភាពជាដៃគូ។ គោលដៅទាំងប្រាំមួយនេះត្រូវបានផ្តល់អាទិភាពផងដែរនៅក្នុងអាទិភាពនៃផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី IV និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ ។ សកម្មភាពគម្រោងនឹងស្ថិតនៅក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាដូចខាងក្រោម៖

- គោលដៅទី១៖ បញ្ចប់ភាពក្រីក្រ
- គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន
- គោលដៅទី៦៖ ទឹកស្អាត
- គោលដៅទី១០៖ កាត់បន្ថយវិសមភាព
- គោលដៅទី១៣៖ ការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ
- គោលដៅទី១៥៖ ជីវិតនៅលើដែនគោក

គម្រោងរេដបូកសំកុសមានគោលបំណងសំខាន់ចំនួន ៣៖

១. អាកាសធាតុ៖ ជៀសវាងការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការកាប់បំផ្លាញ និងការរិចរិលនៃព្រៃឈើ។

២.សហគមន៍៖ បង្កើតឱកាសការងារសមរម្យ ផ្តល់ទឹកស្អាត និងផ្តល់សកម្មភាពកសិកម្មអភិរក្ស ដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ សន្តិសុខស្បៀង និងការពារតំបន់ទេសភាព។

៣. ជីវៈចម្រុះ៖ ការពារ និងរក្សាទីជម្រក ដើម្បីបង្កើនជីវៈចម្រុះ។

គម្រោងរេដបូកសំកុសជំរុញលំហូរហិរញ្ញវត្ថុទៅកាន់ប្រទេសអភិវឌ្ឍន៍តិចតួច គឺប្រទេសកម្ពុជា ដើម្បីកាត់បន្ថយវិសមភាព។ គម្រោងរេដបូកសំកុសដាក់បញ្ចូលទីផ្សារកាបូនស្ម័គ្រចិត្តជាមួយនឹងចូលរួមចំណែករបស់រដ្ឋភាគី និងគាំទ្ររដ្ឋាភិបាល និងសហគមន៍មូលដ្ឋានតាមរយៈហិរញ្ញប្បទានកាបូន។ អត្ថប្រយោជន៍សម្រាប់អាកាសធាតុរបស់គម្រោងរួមមានការជៀសវាងការបំភាយឧស្ម័នប្រចាំឆ្នាំជាមធ្យមចំនួន ១ ៩១១ ៨២៣ តោននៃឧស្ម័នកាបូនឌីអុកស៊ីត ដែលសរុបការជៀសវាងបំភាយឧស្ម័នចំនួន ៥៧ ៣៥៤ ៦៩០ តោននៃឧស្ម័នកាបូនឌីអុកស៊ីត ក្នុងអាយុគម្រោងដែលមានរយៈពេល ៣០ ឆ្នាំ ។

ការអនុវត្តច្បាប់ស្តីពីការអភិរក្សគឺជាឧបករណ៍សំខាន់ដែលប្រើដើម្បីការពារ និងអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិទាំងបីនៅក្នុងគម្រោងរេដបូកសំកុស ។ គម្រោងនេះនឹងផ្តល់ការបណ្តុះបណ្តាលការអនុវត្តច្បាប់ស្តីពីការអភិរក្ស សម្ភារៈល្បាត និងធ្វើឱ្យប្រសើរឡើង និង/ឬសាងសង់ស្នាក់ការសម្រាប់ឧទ្យានុរក្សបន្ថែមក្នុងគោលបំណង ១) ការពារដែនជម្រកសត្វព្រៃ ២) ការត្រួតពិនិត្យ និងប្រមូលទិន្នន័យប្រជាសាស្ត្រចំនួនសត្វព្រៃ ៣) ការលើកកម្ពស់តម្លៃនៃតំបន់ការពារធម្មជាតិដល់ភ្ញៀវទេសចរ និងសហគមន៍មូលដ្ឋាន និង ៤) ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីធានាថាគម្រោងទាំងអស់អនុវត្តតាមគោលការណ៍ណែនាំនៃការអភិរក្ស។ គម្រោងក៏នឹងចាប់ដៃគូជាមួយក្រសួងបរិស្ថាន ដើម្បីផ្តល់ជូនកម្មវិធីបណ្តុះបណ្តាលដល់ឧទ្យានុរក្ស ដើម្បីពង្រឹងជំនាញបច្ចេកទេសរបស់ឧទ្យានុរក្ស ដែលភារកិច្ចរបស់ពួកគេរួមមានការស្វែងរក ការស៊ើបអង្កេត និងការចាប់ជនបង្កមកទទួលខុសត្រូវចំពោះសកម្មភាពបទល្មើសព្រៃឈើ។ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ គឺជាដៃគូយុទ្ធសាស្ត្រអភិរក្សមួយរបស់ក្រសួងបរិស្ថានចាប់តាំងពីឆ្នាំ ២000 មក។

គម្រោងរេដបូកសំកុស នឹងគាំទ្រការកាត់បន្ថយភាពក្រីក្រដោយបង្កើតឱកាសការងារ ដើម្បីគាំទ្រដល់ការកើនឡើងនៃប្រាក់ចំណូលក្នុងគ្រួសារ។ គម្រោងរេដបូកសំកុសនឹងជួយគ្រួសារដែលមានប័ណ្ណក្រីក្រ ហើយនឹងផ្តោតលើការផ្តល់ការងារ និងការគាំទ្រជីវភាពដល់សមាជិកសហគមន៍ដែលខ្វះខាតបំផុត។ កសិកម្មអភិរក្សនឹងជួយកាត់បន្ថយការកាប់ឈើខុសច្បាប់ដោយកសិករ/អ្នកភូមិក្នុងតំបន់ ជំនួសដោយការកែលម្អផលិតភាពកសិកម្ម និងការស្តារឡើងវិញនូវភាពចម្រុះនៃដំណាំ និងបង្កើនលទ្ធភាពទទួលបានទីផ្សារ។ គម្រោងបានកំណត់គ្រួសារជាច្រើននៅក្នុងតំបន់គម្រោងថាមាន "អសន្តិសុខស្បៀង" ដោយយ៉ាងហោចណាស់ ៣ ខែក្នុងមួយឆ្នាំ។ កសិកម្មអភិរក្សនឹងជួយកាត់បន្ថយភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភក្នុងគ្រួសារក្នុងតំបន់គម្រោង ដោយផ្តល់មាន់ និងកង្កែបដល់គ្រួសារក្រីក្របំផុត និងការបណ្តុះបណ្តាលស្តីពីការចិញ្ចឹមសត្វ។ ទាំងនេះគឺផ្តល់ផលប៉ះពាល់បរិស្ថានទាប មានប្រភពអាហារដែលមានប្រូតេអ៊ីនខ្ពស់ ដែលនឹងកាត់បន្ថយការពឹងផ្អែកលើសាច់សត្វព្រៃផងដែរ។

គម្រោងនេះបានកំណត់ទីតាំងចំនួន ៦៨ សម្រាប់ការសាងសង់អណ្តូងទឹកដើរដោយថាមពលពន្លឺព្រះអាទិត្យក្នុងភូមិគោលដៅចំនួន ២៦ ដែលមាន ២៦ អណ្តូងក្នុងខេត្តបាត់ដំបង និង ៤២ នៅខេត្តពោធិ៍សាត់។ គម្រោងនឹងបង្កើតអនុគណៈកម្មការអណ្តូងទឹកមួយសម្រាប់ទីតាំងនីមួយៗ ដើម្បីជួយថែរក្សា និងដោះស្រាយបញ្ហាដែលអាចកើតមាន។ គណៈកម្មការអណ្តូងទឹកសម្រាប់ភូមិទាំងមូលក៏នឹងត្រូវបានបង្កើតឡើងផងដែរ សម្រាប់ការតាមដាន និងត្រួតពិនិត្យអណ្តូងទឹកទាំងអស់នៅក្នុងភូមិរបស់ពួកគេ។

ប្រជាជនជាច្រើនប្រមូលផលបានតិច និង/ឬការលក់មានចំនួនតិចលើផលិតផលកសិកម្មដោយសារមានកូនរដូវប្រាំង ក្នុងរដូវវស្សាមានរយៈពេលយូរ និងការថយចុះទិន្នផលដោយសារការបាត់បង់សារធាតុចិញ្ចឹមរបស់ដីបានជំរុញឱ្យកសិករជាច្រើនបង្ខំចិត្តយកប្រាក់កម្ចីពីភាគីខាងក្រៅ។ ដោយសារតែការថយចុះទិន្នផលពោត និងដំឡូងមី ដែលជាផលិតផលកសិកម្មពីរដែលកសិករក្រីក្រមានលទ្ធភាពដាំដុះ គ្រួសារកសិករមិនអាចបង់ការប្រាក់កម្ចីដែលមានការប្រាក់ខ្ពស់បានទេ។ ដើម្បីជាថ្នូរនឹងការបាត់បង់ប្រភពចំណូលពីវិស័យកសិកម្ម កសិករមួយចំនួនបានឈូសឆាយដីព្រៃដោយខុសច្បាប់ និងកាប់ឈើលក់កាន់តែច្រើនទាំងក្នុង និងក្រៅសហគមន៍រៀងៗខ្លួន រួមទាំងការឆ្លងដែនទៅប្រទេសថៃដើម្បីកាប់ឈើ។

កសិកម្មអភិរក្សមិនត្រឹមតែដោះស្រាយការអនុវត្តដែលត្រូវការដើម្បីបង្កើនផលិតភាពកសិកម្មលើដីស្រែដែលមានស្រាប់ និងស្តារភាពចម្រុះនៃដំណាំប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងជួយការពារស្ថានប្រព័ន្ធរបស់គម្រោងរេដបូកសំកុស ដោយរារាំងអ្នកភូមិពីការកាប់ឆ្ការព្រៃបន្ថែមទៀត ដើម្បីបំពេញតម្រូវការមូលដ្ឋានរបស់គ្រួសារពួកគេ។ លើសពីនេះ កសិកម្មអភិរក្សអាចជួយកែលម្អលទ្ធភាពទទួលបានទីផ្សារ។ ការភ្ជាប់ផលិតផលដែលជួយសំរួលដល់ការអភិរក្សរបស់កសិករទៅនឹងក្រុមដែលកំពុងកើនឡើងនៃអ្នកទិញម្ហូបអាហារដែលមានទំនួលខុសត្រូវជាសាកល អាចជួយឱ្យពួកគេលក់ផលិតផលរបស់ពួកគេបានកាន់តែច្រើនលើសពីតម្លៃធម្មតា។ អ្នកទេសចរណ៍ធម្មជាតិចូលចិត្តទិញ និងប្រើប្រាស់ផលិតផលដែលដាំដុះ និងចែកចាយប្រកបដោយការទទួលខុសត្រូវ។

សូមចូលទៅកាន់គេហទំព័រចុះឈ្មោះរបស់ VERRA https://registry.verra.org/ ឬការិយាល័យគម្រោង ដើម្បីពិនិត្យមើលឯកសារគម្រោងពេ

## ទីតាំងគម្រោង

# ផែនទីតំបន់គម្រោង និងតំបន់សហគមន៍នៃគម្រោងរេដបូកសំកុស




ឧបសម្ព័ន្ធទី១៖ ទីតាំងគម្រោងរេដបូកសំកុស

| ព្រំប្រទល់ | ទីតាំង ( ខាងកើត, ខាងជើង ខ្សែបន្ទាត់និយាមកា ៤៨N) |
|---|---|
| ព្រំប្រទល់ភាគខាងជើង | 305491.20 m E, 1393197.98 m N |
| ព្រំប្រទល់ភាគខាងកើត | 383776.54 m E, 1335440.24 m N |
| ព្រំប្រទល់ភាគខាងត្បូង | 265315.68 m E, 1315715.71 m N |
| ព្រំប្រទល់ភាគខាងលិច | 250874.08 m E, 1384556.10 m N |

## កាលបរិច្ឆេទគម្រោង និងចំណុចសំខាន់ៗគួរគត់សម្គាល់

| កាលបរិច្ឆេទ | ចំណុចសំខាន់ក្នុងការអភិវឌ្ឍន៍ និងការអនុវត្តគម្រោង |
|---|---|
| ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ | កិច្ចខិតខំប្រឹងប្រែងការពារគម្រោងវេជបូកសំកុសបានចាប់ផ្តើម; រយៈពេលគណនេយ្យឧស្ម័នផ្ទះកញ្ចក់បានចាប់ផ្តើម |
| ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ | ស្នាក់ការល្បាតអូរសោម និងស្នាក់ការល្បាតរវៀងបានដំណើរការពេញលេញ |
| ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ | ក្រសួងបរិស្ថាន បានផ្តល់ការអនុម័តចុងក្រោយសម្រាប់គម្រោងវេជបូកសំកុស |
| ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ | ក្រសួងបរិស្ថាន និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីអភិវឌ្ឍ និងអនុវត្តគម្រោងវេជបូកសំកុស |
| ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ | បានចាប់ផ្តើមការសិក្សាពីអណ្តូងទឹកក្នុងតំបន់សហគមន៍គម្រោងវេជបូកសំកុស |
| ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ ២០២៣ | បានរៀបចំការប្រជុំដើម្បីទទួលបានការព្រមព្រៀងដោយសេរី ជាមុន និងមានព័ត៌មាន ចំនួន ២៧ លើក នៅទូទាំងតំបន់គម្រោង |
| ថ្ងៃទី១១ដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ | បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃហេតុប៉ះពាល់សង្គមរបស់គម្រោង<br>វេជបូកសំកុសបានប្រព្រឹត្តទៅនៅក្រុងពោធិ៍សាត់ |
| ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ | ចាប់ផ្តើមការសិក្សាពីជីវភាពនៅក្នុងភូមិជនជាតិដើមភាគតិច (ភ្នំរ៉ែ) |
| ថ្ងៃទី១៤ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ | បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃហេតុប៉ះពាល់ជីវចម្រុះរបស់គម្រោងវេជបូកសំកុសបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ |
| ថ្ងៃទី២២ ខែមិថុនា និងថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ | ស្នាក់ការល្បាតប្រកចង្អៀត និងស្នាក់ការល្បាតថ្មដា បានបើកដំណើរការ |

## ខ្សែសង្វាក់នៃបញ្ហា

### ក. បញ្ហាសំខាន់ទី១): ការកាប់ព្រៃ និងការទន្ទ្រានយកដី

ប្រសិនបើចំណេះដឹងផ្នែកបរិស្ថានត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលា ហើយការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ត្រូវបានធ្វើឡើងសម្រាប់ប្រជាជនមូលដ្ឋានបំណិនជីវិត និងចំណេះដឹងត្រូវបានផ្តល់ជូន ប្រជាជនមូលដ្ឋាននឹងចូលរួមក្នុងការការពារ និងអភិរក្សព្រៃឈើ

ប្រសិនបើវិស័យកសិកម្មផ្សារភ្ជាប់នឹងទីផ្សារ គ្រាប់ពូជត្រូវបានផ្តល់ដល់ប្រជាជនមូលដ្ឋាននូវដើមទុន និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ប្រភពទឹកត្រូវបានសាងសង់ សម្បទានដីសង្គមកិច្ចផ្តល់ដីគ្រប់គ្រាន់ដល់ប្រជាជនមូលដ្ឋាន ការងារត្រូវបានបង្កើត ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាននឹងប្រសើរឡើង

ប្រសិនបើការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពត្រូវបានគាំទ្រដោយប្រជាពលរដ្ឋមូលដ្ឋានជាមួយនឹងការកំណត់ព្រំដែនច្បាស់លាស់ និងវិធានការច្បាប់តឹងរឹង

នោះ ការកាប់ឈើខុសច្បាប់ និងការឈូសឆាយព្រៃឈើសម្រាប់ការទន្ទ្រានយកដីនឹងត្រូវកាត់បន្ថយ ដែលនាំទៅដល់ការបញ្ឈប់ទាំងស្រុង។




### ខ. បញ្ហាសំខាន់ទី២): ខ្វះការចូលរួមពីប្រជាជនក្នុងការងារអភិរក្ស

ប្រសិនបើមានហេដ្ឋារចនាសម្ព័ន្ធល្អនៅនឹងកន្លែង ហើយការចំណាយថយចុះ

ប្រសិនបើមានការអប់រំល្អនៅក្នុងកន្លែងជាមួយនឹងការច្នៃប្រឌិត ហើយព័ត៌មានត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់សហគមន៍ ហើយសេរីភាពនៃការបញ្ចេញមតិ និងអំណាចនៃការសម្រេចចិត្តត្រូវបានផ្តល់ដល់សមាជិកសហគមន៍

ប្រសិនបើមានការគាំទ្រពីស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើនការគ្រប់គ្រងព្រៃឈើក្នុងតំបន់សហគមន៍ការពារធម្មជាតិ សហគមន៍មូលដ្ឋាននឹងស្រឡាញ់ធម្មជាតិ និងផ្តល់កិច្ចសហការល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្តិសុខ និងសុវត្ថិភាពផ្ទាល់ខ្លួន

នោះ សហគមន៍មូលដ្ឋាននឹងចូលរួមក្នុងការការពារ និងអភិរក្សព្រៃឈើ។




## គ. បញ្ហាសំខាន់ទី៣): បញ្ហាជីវភាពក្រីក្រ

បើភូមិឃុំមានសុវត្ថិភាព គ្មានការលេងល្បែងស៊ីសង គ្មានការជួញដូរ និងប្រើប្រាស់គ្រឿងញៀន គ្មានអំពើហិង្សាក្នុងគ្រួសារ សមាជិកគ្រួសាររស់នៅដោយសុខដុមរមនា

ប្រសិនបើមានយុទ្ធសាស្ត្រល្អក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍កសិកម្ម មានការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម សហគមន៍នឹងទទួលបានទិន្នផលកាន់តែប្រសើរ រួមជាមួយនឹងទីផ្សារដ៏ល្អសម្រាប់ផលិតផលកសិកម្ម ហើយផលិតផលនឹងត្រូវលក់ក្នុងតម្លៃខ្ពស់ មានដើមទុនគ្រប់គ្រាន់ និងចំណេះដឹង...

ប្រសិនបើមានគោលនយោបាយ និងការបែងចែកតំបន់ប្រើប្រាស់ដីច្បាស់លាស់ សមាជិកសហគមន៍មានសិទ្ធិទទួលបានដីសម្បទានសង្គមកិច្ច ដែលមានដីគ្រប់គ្រាន់សម្រាប់ធ្វើស្រែ

ប្រសិនបើការអភិវឌ្ឍន៍មាននិរន្តរភាព ព្រៃឈើត្រូវបានការពារយ៉ាងល្អ គ្រោះធម្មជាតិកើតឡើងតិច សហគមន៍មូលដ្ឋានប្រមូលផលបានច្រើន

ប្រសិនបើមានការអភិវឌ្ឍន៍ធនធានមនុស្ស សហគមន៍នីមួយៗមានសាលារៀន ប្រជាជនមានការអប់រំល្អ និងចំណេះដឹងក្នុងការអភិវឌ្ឍន៍គ្រួសារ

ប្រសិនបើសុខុមាលភាពសង្គមល្អ អនាម័យល្អ អាហារូបត្ថម្ភ និងអាហារគ្រប់គ្រាន់ គ្រួសារមានសុខភាពល្អ និងប្រសិនបើប្រជាជនមូលដ្ឋានមានការងារសមរម្យ

នោះជីវភាពរបស់ប្រជាជនមូលដ្ឋាននឹងប្រសើរឡើង។




| | | | | |
|---|---|---|---|---|
| សញ្ញាសម្គាល់ | យុទ្ធសាស្ត្រ | លទ្ធផលដែលទទួលបានភ្លាមៗ | លទ្ធផលកាត់បន្ថយការគំរាមកំហែង | គោលដៅ |

ឧបសម្ព័ន្ធទី២៖ ខ្សែសង្វាក់លទ្ធផលដែលគូសបញ្ជាក់ពីទ្រឹស្តីនៃការផ្លាស់ប្តូរសម្រាប់បញ្ហាសំខាន់ៗចំនួនបីដែលបានកំណត់ក្នុងអំឡុងពេលសិក្ខាសាលាស្តីពីការវាយតម្លៃហេតុប៉ះពាល់សង្គមសម្រាប់គម្រោងរេដបូកសំកុស។